THE SCHOOL DISTRICT OF PHILADELPHIA
**Office of Student Enrollment and Placement**
Suite 111
440 North Broad Street
Philadelphia, PA 19130

# សាលាបឋមសិក្សា Penn Alexander
# ដំណើរការចុះឈ្មោះសិស្សមត្តេយ្យ ឆ្នាំសិក្សា 2021-2022

ខាង ក្រោមនេះគឺជាគោលការណ៍ណែនាំនិងពេលវេលាកំណត់ដែលនឹងត្រូវគ្រប់គ្រងលើរបៀបដែលដំណើរការនៃការដាក់ពាក្យ និងជ្រើសរើសត្រូវធ្វើឡើងដើម្បីចុះឈ្មោះសិស្សចូលរៀនថ្នាក់មត្តេយ្យនៃសាលាបឋមសិក្សា Penn Alexander (PAS) សម្រាប់ឆ្នាំសិក្សា 2021-2022។ **ពាក្យទាំងអស់ត្រូវតែផ្ញើតាមប្រព័ន្ធចុះឈ្មោះតាមអនឡាញ។**

| កាលវិភាគដំណើរការចាប់ឆ្នោតសាលាមត្តេយ្យ Penn Alexander | |
|---|---|
| កាលបរិច្ឆេទចុះឈ្មោះ | ថ្ងៃចន្ទទី 19 ខែមករាឆ្នាំ 2021 ដល់ថ្ងៃសុក្រ ទី 5 ខែកុម្ភៈ ឆ្នាំ 2021 |
| បុគ្គលិកសាលាផ្ញើបញ្ជីចុងក្រោយទៅ OSEP តាមរយៈអ៊ីមែល។ | ថ្ងៃសុក្រទី 10 ខែកុម្ភៈ ឆ្នាំ 2021 |
| មណ្ឌលសិក្សាដំណើរការពាក្យសុំ | ថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2021 – ថ្ងៃទី 19 ខែកុម្ភៈ ឆ្នាំ 2021 |
| សំបុត្រឆ្នោតបានផ្ញើទៅគេហដ្ឋានរបស់សិស្ស៖ | ថ្ងៃសុក្រ ទី 26 ខែកុម្ភៈ ឆ្នាំ 2021 |

## គោលការណ៍ណែនាំជាទូទៅ

- មានតែកូនសិស្សដែលរស់នៅក្នុងតំបន់ PAS ប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងកម្មវិធីចាប់ឆ្នោត។ ពាក្យទាំងអស់ដែលបានទទួលបន្ទាប់ពីការបិទរយៈពេលចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យនឹងត្រូវបានបញ្ចូលក្នុងបញ្ជីរង់ចាំ ហើយនឹងមិនយកទៅពិចារណានៅក្នុងដំណើរការចាប់ឆ្នោតទេ។ ពាក្យនឹងត្រូវដាក់ចូលទៅក្នុងបញ្ជីរង់ចាំតាមលំដាប់លំដោយដែលទទួលដោយចាប់ផ្ដើមពីលេខដំបូងបន្ទាប់ពីការចាប់ឆ្នោតធ្វើឡើងសម្រាប់សិស្ស។ ពាក្យត្រូវបានចាត់ទុកថាពេញលេញនៅពេលដែលត្រូវបានគូសសញ្ញាសម្គាល់បញ្ជាក់ថាបានបំពេញដោយលេខាធិការសាលា។

- ទាមទារឯកសារចំនួនពីរច្បាប់ដែលបញ្ជាក់ពីការរស់នៅក្នុងតំបន់ខាងលើនេះនៅពេលដាក់ឯកសារចុះបញ្ជីដែលមានឯកសារមួយជាប័ណ្ណកម្មសិទ្ធិ កិច្ចសន្យាជួលដែលបញ្ជាក់ដោយសាការី វិក្កយបត្រសេវាសាធារណៈ ឬព័ត៌មានដែលចេញដោយរដ្ឋាភិបាល។ <u>វិក្កយបត្រទឹក លិខិតបញ្ជាក់ការស្នាក់នៅ និងលិខិតផ្ទេរសិទ្ធិនៃទំនួលខុសត្រូវរបស់ឪពុកម្ដាយនឹងមិនទទួលយកទេ។</u> រាល់ព័ត៌មានដែលរាប់បញ្ចូលទាំងការចាក់ថ្នាំបង្ការត្រូវតែដាក់ជូនដើម្បីយកមកពិចារណា។ រាល់ពាក្យដែលបំពេញតាមលក្ខខណ្ឌនៃការស្នាក់នៅនឹងត្រូវដាក់ក្នុងកម្មវិធីចាប់ឆ្នោត។

- សេចក្ដីជូនដំណឹងនេះនឹងត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ និងត្រូវបានដាក់នៅលើគេហទំព័រមណ្ឌលសិក្សានៅពេលដែលមណ្ឌលសិក្សាប្រកាសការចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យនៅ ឬមុនថ្ងៃទី 11 ខែមករា។ សេចក្ដីជូនដំណឹងទាំងអស់នឹងត្រូវបកប្រែទៅជាភាសាសំខាន់ទាំងប្រាំបីរបស់មណ្ឌលសិក្សា។

- រាល់ទម្រង់ចុះឈ្មោះត្រូវតែដាក់ជូន PAS នៅថ្ងៃផុតកំណត់ ឬមុនថ្ងៃផុតកំណត់។ ប្រព័ន្ធនេះនឹងលែងទទួលយកពាក្យនៅម៉ោង 11:59 យប់ ថ្ងៃសុក្រទី 5 ខែកុម្ភៈ ឆ្នាំ 2021។

THE SCHOOL DISTRICT OF PHILADELPHIA **Office of Student Enrollment and Placement**
Suite 111
440 North Broad Street
Philadelphia, PA 19130

**សាលាបឋមសិក្សា Penn Alexander**
**ដំណើរការចុះឈ្មោះសិស្សមត្តេយ្យ ឆ្នាំសិក្សា 2021-2022**

- រាល់ការសម្រេចចិត្តចុះឈ្មោះនឹងត្រូវបានផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរតាមរយៈអ៊ីមែលទៅកាន់អាសយដ្ឋានអ៊ីមែលដែលប្រើក្នុងការបំពេញពាក្យសុំ។ ការសម្រេចចិត្តអំពីការចុះឈ្មោះចូលរៀននឹងមិនត្រូវបានផ្សព្វផ្សាយតាមទូរសព្ទ ហើយក៏មិនផ្ញើលិខិតទៅឪពុកម្ដាយដោយសាលា Penn Alexander ឬមជ្ឈមណ្ឌលអប់រំរបស់មណ្ឌលសិក្សាដែរ។
- ចំពោះព័ត៌មានបន្ថែមស្ដីពីដំណើរការចុះឈ្មោះតាមអនឡាញ សូមចូលមើលគេហទំព័រ www.philasd.org/studentplacement/registration

## ភស្តុតាងបញ្ជាក់អាសយដ្ឋាន

***ភស្តុតាងបញ្ជាក់អាសយដ្ឋាន (ទាមទារឯកសារចំនួនពីរ (2) ដូចខាងក្រោម)***
ឯកសារដែលអាចទទួលយកបានរួមមានដូចខាងក្រោម៖ ឯកសារមួយក្នុងចំណោមឯកសារទាំងអស់ត្រូវតែជាប័ណ្ណកម្មសិទ្ធិ កិច្ចសន្យាជួលដែលបញ្ជាក់ដោយសាការី ឬវិក្កយបត្រសេវាសាធារណៈ។ រាល់ព័ត៌មានអំពីការស្នាក់នៅនឹងត្រូវបានផ្ទៀងផ្ទាត់ដើម្បីភាពត្រឹមត្រូវ។ ព័ត៌មានបន្ថែមអាចត្រូវបានទាមទារក្នុងអំឡុងពេលដំណើរការផ្ទៀងផ្ទាត់។

| | |
|---|---|
| ប័ណ្ណកម្មសិទ្ធិ | អត្តសញ្ញាណប័ណ្ណ DOT ដែលមានសុពលភាព |
| តារាងទូទាត់ប្រាក់សម្រាប់វត្ថុបញ្ចាំ | វិក្កយបត្រកាតឥណទានបច្ចុប្បន្ន |
| វិក្កយបត្រសេវាសាធារណៈបច្ចុប្បន្ន (ហ្គាស ភ្លើង) | ការចុះឈ្មោះយានយន្តថ្មីៗនេះ |
| វិក្កយបត្របង់ពន្ធអចលនទ្រព្យថ្មីៗនេះ | ប័ណ្ណចុះឈ្មោះបោះឆ្នោតដែលបង្ហាញអាសយដ្ឋានបច្ចុប្បន្ន |
| ប័ណ្ណបើកបរដែលមានសុពលភាព ឬប័ណ្ណផ្លាស់ប្ដូរអាសយដ្ឋានដែលមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក | របាយការណ៍ហិរញ្ញវត្ថុធនាគារថ្មីៗនេះដែលមានអាសយដ្ឋានបច្ចុប្បន្ន |
| លិខិតពីការិយាល័យសន្តិសុខសង្គមដែលមានអាសយដ្ឋានបច្ចុប្បន្ន | របាយការណ៍ IRS ឬលិខិតបញ្ជាក់ប្រាក់ឈ្នួលនិងពន្ធផ្សេងទៀត ឧ. ដូចជាទម្រង់ W2, 1040, 1099 |
| លិខិតពីការិយាល័យជំនួយសាធារណៈដែលមានអាសយដ្ឋានបច្ចុប្បន្ន | ចុងសន្លឹកប័ណ្ណបើកប្រាក់ខែរបស់និយោជកនាពេលថ្មីៗនេះដែលបង្ហាញអាសយដ្ឋានបច្ចុប្បន្ន |

THE SCHOOL DISTRICT OF PHILADELPHIA
**Office of Student Enrollment and Placement**
Suite 111
440 North Broad Street
Philadelphia, PA 19130

**សាលាបឋមសិក្សា Penn Alexander**
**ដំណើរការចុះឈ្មោះសិស្សមត្តេយ្យ ឆ្នាំសិក្សា 2021-2022**

| | |
|---|---|
| លិខិតបញ្ជាក់ពីកន្លែងថែទាំ/ចិញ្ចឹមកុមារ និងលិខិត DHS អាចទទួលយក បានសម្រាប់ការចុះឈ្មោះនៅពេលដែលកូនសិស្សកំពុងស្ថិត ក្រោមការមើលថែរបស់ទីភ្នាក់ងារថែទាំ/ចិញ្ចឹមកុមារ | កិច្ចសន្យាជួលច្បាប់ដើមដែលមានឈ្មោះឪពុកម្តាយ/អាណាព្យាបាលស្របច្បាប់ និងកុមារ |
| កិច្ចព្រមព្រៀងស្តីពីការលក់អចលនទ្រព្យដែលបានចុះហត្ថលេខា បន្ទាប់មក គឺឯកសារទូទាត់ប្រាក់ច្បាប់ដើមក្នុងរយៈពេល 45 ថ្ងៃទូទាត់ | |